# I- ទីស្តីការគណៈរដ្ឋមន្ត្រី

## ១- អនុក្រឹត្យ

*រាជធានីភ្នំពេញ ,ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៥*

### អនុក្រឹត្យលេខ ០១ អនក្រ

**ស្តីពីការលុបចោលអនុក្រឹត្យបង្កើតគណៈកម្មាធិការអចិន្ត្រៃយ៍ចំរុះអន្តរក្រសួង ទប់ស្កាត់បទល្មើសព្រៃឈើបទល្មើសនេសាទបទល្មើសកាប់ដើមកៅស៊ូនិងដឹកជញ្ជូនជ័រកៅស៊ូ និង សេចក្តីសំរេចស្តីពីការបង្កើតគណៈកម្មការស្រាវជ្រាវត្រួតពិនិត្យបាតុភាពឈើមូល ឈើអារ**

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងស្មារតីអង្គប្រជុំអន្តរក្រសួង ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៤

### សំរេច

**មាត្រា ១ :** លុបចោល

-អនុក្រឹត្យលេខ ០២ អនក្រ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតគណៈកម្មាធិការអចិន្ត្រៃយ៍ចំរុះ អន្តរក្រសួងទប់ស្កាត់បទល្មើសព្រៃឈើ បទល្មើសនេសាទ បទល្មើសកាប់ដើមកៅស៊ូ និង ដឹកជញ្ជូនជ័រកៅស៊ូ ។

-សេចក្តីសំរេចលេខ ៧៨ សសរ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតគណៈកម្មការស្រាវជ្រាវត្រួត ពិនិត្យឈើមូល ឈើអារ ។

www.pheakdeylaw.com

-សេចក្តីសំរេចលេខ ៨៨ សសរ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសេចក្តីសំរេចលេខ ៧៨ សសរ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។

**មាត្រា ២ :** ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីអនុវត្តតាមគោលការណ៍ថ្មី របស់រាជរដ្ឋាភិបាល និង អនុវត្តការងារទាំងឡាយដែលនៅសេសសល់ពីគណៈកម្មការស្រាវជ្រាវត្រួតពិនិត្យឈើមូល ឈើអារ ។ ក្នុងករណីចាំបាច់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទអាចស្នើសុំកំលាំងរបស់ក្រសួងមានសមត្ថកិច្ច ដើម្បីចូលរួមក្នុងប្រតិបត្តិការ ។

**មាត្រា ៣ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សហប្រធាន គណៈកម្មការស្រាវជ្រាវត្រួតពិនិត្យឈើមូល ឈើអារ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុក អនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និងត្រា | ហត្ថលេខា និងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៥*

## អនុក្រឹត្យលេខ ០២ អនក្រ
## ស្តីពីការធ្វើនិយ័តភាពថវិកា ឆ្នាំ ១៩៩៤
## ពីជំពូក ១០ ទៅជំពូក ១១

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

www.pheakdeylaw.com